ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ: ២៨៦៩ ប្រ.ក

# ប្រកាស
## ស្តីពី
## ការកែសម្រួលសមាសភាពក្រុមការងារយេនឌ័ររបស់ក្រសួងមហាផ្ទៃ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែឧសភា ឆ្នាំ២០០៨ ដែលបានប្រកាសឲ្យប្រើ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ

-បានឃើញប្រកាសលេខ ៤៣៩៩ ប្រក ចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០១២ ស្តីពីការកែសម្រួលសមាសភាពក្រុមការងារយេនឌ័ររបស់ក្រសួងមហាផ្ទៃ

-យោងតាមសំណូមពរចាំបាច់របស់ក្រសួងមហាផ្ទៃ

## សម្រេច

**ប្រការ១.** រៀបចំកែសម្រួលសមាសភាពក្រុមការងារយេនឌ័ររបស់ក្រសួងមហាផ្ទៃដូចខាងក្រោម៖

១-លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការ ប្រធាន

២-លោកជំទាវ **ជួញ សុនៃ** អនុរដ្ឋលេខាធិការ អនុប្រធានអចិន្ត្រៃយ៍

៣-លោកជំទាវឧត្តមសេនីយ៍ឯក **យក់ សុខា** អគ្គស្នងការរងនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អនុប្រធាន

៤-លោកជំទាវឧត្តមសេនីយ៍ឯក **អ៊ុំ លក្ខិណា** អគ្គនាយករងនៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ អនុប្រធាន

៥-លោកជំទាវ **មឿង ស៊ាងសេង** អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាន សមាជិកា

៦-លោកជំទាវឧត្តមសេនីយ៍ឯក ឌុច ដាណា អគ្គនាយករងនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម សមាជិកា

៧-លោកជំទាវឧត្តមសេនីយ៍ឯក ព្រំ ចន្ថា អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាន សមាជិកា

៨-លោកជំទាវឧត្តមសេនីយ៍ឯក សុខ ចន្ទីរ៉ា អគ្គនាយករងនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ សមាជិកា

៩-លោកជំទាវឧត្តមអគ្គានុរក្សថ្នាក់លេខ១ សុខ សម្បត្តិ អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធនាគារ សមាជិកា

១០-លោកជំទាវ ហាន សុគន្ធា អនុប្រធានក្រុមប្រឹក្សានីតិកម្ម សមាជិកា

១១-លោកជំទាវ នៅ សុខម៉ារ៉ា អគ្គនាយករងអគ្គនាយកដ្ឋានរដ្ឋបាល សមាជិកា

១២-លោកជំទាវ ឡាយ អូនរី អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាល សមាជិកា

១៣-លោកជំទាវឧត្តមសេនីយ៍ឯក ថន សុវណ្ណច័ន្ទខេម៉ា អនុប្រធានបណ្ឌិត្យសភានគរបាលជាតិកម្ពុជា សមាជិកា

១៤-លោកជំទាវឧត្តមសេនីយ៍ទោ គា ម៉ាន់លី អគ្គាធិការរងនៃអគ្គាធិការដ្ឋាន សមាជិកា

១៥-លោកជំទាវឧត្តមសេនីយ៍ទោ ប៉ុណ្ណ សំខាន់ អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សមាជិកា

១៦-ឯកឧត្តម ឧត្តមសេនីយ៍ទោ យ៉ែម ច័ន្ទណារ៉ុ អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សមាជិក

១៧-លោកជំទាវឧត្តមសេនីយ៍ទោ ទៀ តាវ៉ាសាត អគ្គនាយករងនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង សមាជិកា

១៨-លោកជំទាវ ទីរក្សេ ទិដ្ឋនី អគ្គាធិការរងនៃអគ្គាធិការដ្ឋាន សមាជិកា

១៩-លោកជំទាវ រ៉ែន សិរីលក្ខិណា អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សមាជិកា

២០-លោកជំទាវឧត្តមអគ្គានុរក្សថ្នាក់លេខ២ ញ៉ែម អូន អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធនាគារ សមាជិកា

២១-លោក ខោល យុទ្ធលី អនុប្រធានអង្គភាពវិភាគគោលនយោបាយ និងអភិវឌ្ឍ នៃលេខាធិការដ្ឋាន គ.ជ.អ.ប សមាជិក

២២-លោកស្រី ឈឹម សិទ្ធិបុណ្យរិទ្ធ ប្រធានមន្ទីរនៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ សមាជិកា

**ប្រការ២**: ក្រុមការងារយេនឌ័រក្រសួងមហាផ្ទៃមានភារកិច្ចដូចខាងក្រោម៖

-ដឹកនាំ ទំនាក់ទំនង សហការជាមួយអង្គភាពក្រោមឱវាទក្រសួង ក្រុមការងារយេនឌ័រនៃបណ្តាក្រសួង និងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ព្រមទាំងអង្គការសង្គមស៊ីវិលនានា ក្នុងគោលដៅលើកកម្ពស់សមភាពយេនឌ័រ និងលុបបំបាត់អំពើហិង្សាលើស្ត្រីគ្រប់រូបភាព ។

-ប៉ាន់ប្រមាណ និងវាយតម្លៃលទ្ធផលការងារបញ្ជ្រាបយេនឌ័រ តាមបណ្តាអង្គភាពថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិរៀងរាល់ឆមាស និងធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ។

-ចូលរួមផ្សព្វផ្សាយ និងពិនិត្យលើការអនុវត្តអនុសញ្ញាស៊ីដរ (CEDAW) គោលនយោបាយជាតិពាក់ព័ន្ធ នឹងយេនឌ័រ ។

-សម្របសម្រួលការបញ្ជ្រាបយេនឌ័រទៅក្នុងផែនការយុទ្ធសាស្ត្រ គោលនយោបាយ កម្មវិធីទៅគ្រប់អង្គភាពចំណុះរចនាសម្ព័ន្ធរបស់ក្រសួង និងរាជធានី-ខេត្ត ដើម្បីធានាការផ្តល់សេវាជូនប្រជាពលរដ្ឋប្រកបដោយសមធម៌ ។

-បន្តរៀបចំផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ រយៈពេលវែង មធ្យម ផែនការសកម្មភាពនិងគំរោងថវិកាប្រចាំឆ្នាំសម្រាប់ការគាំទ្រពីថវិកាជាតិ ។

-ផ្សព្វផ្សាយផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រឲ្យបានជ្រួតជ្រាប ទូលំទូលាយ ដើម្បីបង្កើនការយល់ដឹងដល់មន្ត្រីគ្រប់លំដាប់ថ្នាក់ និងពង្រឹងសមត្ថភាពទាំងមន្ត្រីរាជការ និងនគរបាលជាតិជានារីដែលអនុវត្តភារកិច្ចដើម្បីបង្កើនឋានៈតួនាទីរបស់ខ្លួន ។

-រៀបចំនីតិវិធីសម្រាប់ការបង្កើនចំនួនមន្ត្រីរាជការស៊ីវិល និងនគរបាលជាតិជានារីនៅគ្រប់កម្រិតទាំងការសម្របសម្រួល និងជំរុញការអនុវត្តន៍ផែនការទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

-គៀងគរការចូលរួមគាំទ្រធនធានថវិកា សម្ភារៈ មធ្យោបាយបច្ចេកទេស កិច្ចសហការពីបណ្តាដៃគូអភិវឌ្ឍន៍ជាតិ អន្តរជាតិ ក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីពង្រឹងពង្រីកសមត្ថភាពយេនឌ័រ និងអនុវត្តផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័ររបស់ក្រសួងឲ្យមានប្រសិទ្ធិភាព ។

-រៀបចំរបាយការណ៍ប្រចាំឆ្នាំស្តីពីលទ្ធផល នៃការលើកកម្ពស់សមភាពយេនឌ័រ ការប្រឈម និងទិសដៅ ដើម្បីដាក់ជូនថ្នាក់ដឹកនាំពិនិត្យសម្រេច និងសុំមតិដឹកនាំ។

-រៀបចំកិច្ចប្រជុំ សិក្ខាសាលា និងវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាព សមាជិកក្រុមការងារយេនឌ័រ និងមន្ត្រីអនុវត្ត។

-តាមដានត្រួតពិនិត្យ វាយតម្លៃលទ្ធផល នៃការអនុវត្តន៍គោលនយោបាយលើកកម្ពស់ សមត្ថភាពយេនឌ័រយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

-ក្រុមការងារយេនឌ័រក្រសួង ត្រូវប្រជុំពិភាក្សាការងាររៀងរាល់មួយត្រីមាសម្តង ជាទៀងទាត់ជាមួយក្រុមការងារយេនឌ័រអង្គភាពចំណុះក្រសួងមហាផ្ទៃ និងរាជធានី-ខេត្ត ដើម្បីពិនិត្យវឌ្ឍនភាព នៃការងារយេនឌ័រ ការប្រឈម និងទិសដៅ។

**ប្រការ៣:** ក្រុមការងារយេនឌ័រក្រសួងមានលេខាធិការដ្ឋានមួយជាសេនាធិការដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១-លោកជំទាវឧត្តមសេនីយ៍ទោ | **ប៉ណ្ណ សំខាន់** | ប្រធានលេខាធិការដ្ឋាន |
| ២-ឯកឧត្តម ឧត្តមសេនីយ៍ទោ | **យ៉េម ច័ន្ទណារុំ** | អនុប្រធានលេខាធិការដ្ឋាន |
| ៣-លោកជំទាវ | **រ៉ែន សិរីលក្ខិណា** | អនុប្រធានលេខាធិការដ្ឋាន |
| ៤-លោកឧត្តមសេនីយ៍ត្រី | **គង់ ពុទ្ធី** | សមាជិក |
| ៥-លោក | **ឆេង ចណ្ណា** | សមាជិក |
| ៦-លោកអនុសេនីយ៍ឯក | **អ៊ិន មាន** | សមាជិក |
| ៧-កញ្ញាអនុសេនីយ៍ឯក | **អ៊ីង ស៊ូគីម** | សមាជិកា |
| ៨-លោកស្រីអនុសេនីយ៍ត្រី | **ថោង សុខត្តី** | សមាជិកា |

លេខាធិការដ្ឋានមានភារកិច្ច៖

- ជាជំនួយការប្រធាន និងក្រុមការងារយេនឌ័រក្រសួងមហាផ្ទៃ ក្នុងការសម្របសម្រួលការងាររដ្ឋបាល ប្រមូលរបាយការណ៍ បូកសរុបរបាយការណ៍ និងរៀបចំរាល់កិច្ចប្រជុំ ។
- រៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ផែនការសកម្មភាពនិងគំរោងថវិកាប្រចាំឆ្នាំ ជូនក្រុមការងារយេនឌ័រ ពិនិត្យ និងអនុម័ត ។
- រៀបចំផែនការ សម្របសម្រួលជាមួយក្រុមការងារយេនឌ័រ បណ្តាអង្គភាពចំណុះក្រសួងមហាផ្ទៃ នៃរាជធានី ខេត្ត ដើម្បីពង្រឹងសមត្ថភាពមន្ត្រីរាជការទាំងស៊ីវិល និងនគរបាលជាតិ ក្នុងការអនុវត្តយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័ររបស់ក្រសួង ។
- បំពេញភារកិច្ចដ៏ទៃទៀត តាមការណែនាំ ចាត់តាំងរបស់ប្រធានក្រុមការងារយេនឌ័រក្រសួងមហាផ្ទៃ ។

**ប្រការ៤:** អង្គភាពចំណុះក្រសួងមហាផ្ទៃ រាជធានី-ខេត្ត ត្រូវរៀបចំបង្កើតក្រុមការងារយេនឌ័រ របស់ខ្លួន និងការិយាល័យទំនាក់ទំនងការងារយេនឌ័រមួយដើម្បីជាជំនួយការអោយក្រុមការងាររបស់អង្គភាព និងដើម្បីទំនាក់ទំនងការងារជាមួយលេខាធិការដ្ឋានក្រុមការងារយេនឌ័រក្រសួង។

**ប្រការ៥:** ក្រុមការងារយេនឌ័ររបស់បណ្តាអង្គភាពចំណុះក្រសួងមហាផ្ទៃ និងរាជធានី-ខេត្ត ត្រូវប្រជុំពិភាក្សាការងាររៀងរាល់មួយខែម្តង និងបញ្ជូនរបាយការណ៍លទ្ធផល នៃការអនុវត្តន៍សកម្មភាពប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ មកលេខាធិការដ្ឋានក្រុមការងារយេនឌ័រក្រសួងដើម្បីបូកសរុប។

**ប្រការ៦:** ក្រុមការងារយេនឌ័រអង្គភាពចំណុះក្រសួង ត្រូវរៀបចំផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ផែនការសកម្មភាព និងផែនការថវិកាប្រចាំឆ្នាំ សំរាប់ការអនុវត្តសកម្មភាពការងាររបស់ខ្លួនបញ្ជូនមក លេខាធិការដ្ឋានក្រុមការងារយេនឌ័រក្រសួង ដើម្បីបូកសរុប។

**ប្រការ៧:** ក្រុមការងារយេនឌ័រ រាជធានី-ខេត្ត ត្រូវរៀបចំផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងផែនការថវិកាប្រចាំឆ្នាំ ដោយបញ្ចូលទៅក្នុងកញ្ចប់ថវិកា រាជធានី-ខេត្ត សម្រាប់អនុវត្តសកម្មភាពការងារយេនឌ័រ និងបញ្ជូនមកក្រុមការងារយេនឌ័រក្រសួងដើម្បីសរុប និងផ្តល់ការណែនាំ និងទិសដៅ ប្រសិនបើចាំបាច់។

**ប្រការ៨:** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះទុកជានិរាករណ៍ ។

**ប្រការ៩:** អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ ប្រធានបណ្ឌិត្យសភានគរបាលជាតិកម្ពុជា អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង អគ្គាធិការនៃអគ្គាធិការដ្ឋាន អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ប្រធានក្រុមប្រឹក្សានីតិកម្ម គណៈអភិបាលរាជធានី ខេត្ត គ្រប់អង្គភាព ចំណុះក្រសួងមហាផ្ទៃ និងលោកជំទាវ ឯកឧត្តម លោក លោកស្រី ដែលមានឈ្មោះក្នុងប្រការ១ ប្រការ៣ មានភារកិច្ច អនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

*ភ្នំពេញ,ថ្ងៃទី ២៥ ខែ ៣ ឆ្នាំ ២០១៦*

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

<u>កន្លែងទទួល:</u>

*-ទីស្តីការគណៈរដ្ឋមន្ត្រី*
*-ក្រសួងកិច្ចការនារី*
*-ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី*
*-ខុទ្ទកាល័យសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ*
*-ដូចប្រការ៩ "ដើម្បីអនុវត្ត"*
*-ឯកសារកាលប្បវត្តិ*